ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ

សូមគោរពជូន

សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបង្ហើរជន្មាយុគម្រប់ ៧២ ឈានចូល ៧៣ឆ្នាំ

សម្តេចកិត្តិសង្គហបណ្ឌិត ជាទីគោរពជ្រះថ្លាខ្ពស់!

នាវិកាសដ៏មហានក្ខត្តឫក្ស ក្នុងពិធីបង្ហើរជន្មាយុគម្រប់ ៧២ ឈានចូល ៧៣ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ៦ រោច ខែស្រាពណ៌ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៥ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសេចក្តីសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្តេចកិត្តិសង្គហបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរ ពន្ធាំងមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ។

ឆ្លៀតក្នុងវិកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះ **សម្តេចកិត្តិសង្គហបណ្ឌិត** ដែលជាតំណាងរាស្ត្រជនស្ត្រីកំពូលមួយរូបរបស់កម្ពុជា តែងខិតខំប្រើងប្រែងយកអស់កម្លាំងកាយចិត្ត ព្រាវ្យា ស្មារតី ណ្ឌសរ៉ាវ៉ៃ ប្ញសប ប្ញកបដោយភាពមោះមុតស្វាហាប់ ស្មោះត្រង់ ក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមបម្រើឱ្យឧត្តមប្រយោជន៍ ជាតិ សាសនា ព្រះមហាក្សត្រ។ ទន្ទឹមគ្នានេះ ក្តីមានជ្ជ័ឧត្តមរបស់ **សម្តេចកិត្តិសង្គហបណ្ឌិត** ដែលបានចុះសាកសួរសុខទុក្ខដល់កងកម្លាំងជួរមុខតាមបណ្តាយខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងពេលកន្លងមកនេះ គឺជាកត្តាជំរុញកម្លាំងចិត្តដ៏ខ្លាំងក្លាដល់នាយទាហាន នាយទាហានរង និងពលទាហានក្នុងការបំពេញបេសកកម្មការពារនូវអធិបតេយ្យភាព និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសត្ថសាធុការពរជ័យ សិរីមង្គល ជូន **សម្តេចកិត្តិសង្គហបណ្ឌិត** ព្រមទាំងយុវ្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** **នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ[illegible] ១[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ [illegible] ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី ជ្រើមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ សីហា

ទីហ្សកនីមិត្ត្រ សង្កាត់មិត្តភាព ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២០០ email: generalsec@mod.gov.kh

អរគុណសន្ធិភាព! អរគុណនយោបាយឈ្នះឈ្នះ!